# សុន្ទរកថា
# សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
# ក្នុងពិធីបើកវេទិកា
# ស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលលើកទី៤
# ថ្ងៃចន្ទ ១០កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
# រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០

- **គណៈអធិបតី**
- **ឯកឧត្តម លោកជំទាវ តំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា**
- **ឯកឧត្តម លោកជំទាវអភិបាលរាជធានី ខេត្ត**
- **ឯកឧត្តម លោក លោកស្រី តំណាងដៃគូអភិវឌ្ឍន៍នានា**
- **ភ្ញៀវកិត្តិយស មន្ត្រីរាជការ អស់លោក លោកស្រីតំណាងអង្គការសង្គមស៊ីវិល សមាជិក សមាជិកា នៃអង្គវេទិកាទាំងមូល ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកចូលរួមជាមួយនឹងឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលអញ្ជើញមកពីក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល រដ្ឋបាលរាជធានី ខេត្ត តំណាងអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា ក្នុងពិធីបើកវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលលើកទី៤ នាឱកាសដ៏ថ្លៃថ្លានេះ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងនាមរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានរបស់គណៈអធិបតី ភ្ញៀវកិត្តិយស ឯកឧត្តម លោកជំទាវ លោក លោកស្រីជាសមាជិក សមាជិកា នៃអង្គវេទិកាទាំងមូលដែលបានឆ្លៀតពេលវេលាដ៏មានតម្លៃ និងមមាញឹក ដើម្បីចូលរួមក្នុងវេទិកា

លើកទី៤ នាពេលនេះ។ ជាមួយគ្នានេះ ខ្ញុំសូមរំលឹកជូនអង្គវេទិកាទាំងមូលផងដែរថា វេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលលើកទី៣ ត្រូវបានរៀបចំឡើងកាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩។ បន្ទាប់ពីពិធីបើកនាពេលបន្តិចទៀតនេះ អគ្គនាយក-ដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ នឹងធ្វើសេចក្តីរាយការណ៍អំពីវឌ្ឍនភាពការងារ ចាប់ពីវេទិកាលើកទី៣កន្លងមក រហូតដល់វេទិកាលើកទី៤ ជូនដល់សមាជិក សមាជិកានៃអង្គវេទិកាដើម្បីជ្រាបជាព័ត៌មាន។

- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាទីមេត្រី!**

ប្រទេសកម្ពុជាយើងប្រកាន់យករបបលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស បើផ្អែកតាមមាត្រា ៥១ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជាគ្មានជម្រើសអ្វីក្រៅពីការបន្តប្តេជ្ញាចិត្តក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងលំហាននយោបាយ តាមរយៈការបើកចំហ និងពិគ្រោះយោបល់ជាមួយគ្រប់តួអង្គពាក់ព័ន្ធនានានៅក្នុងសង្គម ក្នុងដំណើរការដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍសេដ្ឋកិច្ចសង្គមនោះឡើយ។ ជាក់ស្តែង សមិទ្ធផលនៃការរីកចម្រើន និងការអភិវឌ្ឍប្រទេសជាតិដែលរាជរដ្ឋាភិបាលសម្រេចបាននាពេលកន្លងមក និងរហូតដល់ពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកថា ពិតជាមានការចូលរួមចំណែកពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងនោះមានដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការសង្គមស៊ីវិលផងដែរ ជាពិសេសអង្គការសង្គមស៊ីវិលទាំងក្នុងស្រុក និងបរទេស បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ និងគាំទ្រដល់វិស័យសេវាសង្គមនៅតាមមូលដ្ឋានជនបទ និងសហគមន៍ដាច់ស្រយ៉ាលដែលប្រជាពលរដ្ឋមានអត្រាភាពក្រីក្រខ្ពស់។ ទន្ទឹមនេះ អង្គការសង្គមស៊ីវិលក៏បានចូលរួមធ្វើសកម្មភាពក្នុងវិស័យកំណែទម្រង់នានារបស់រដ្ឋ ដូចជា ការលើកកម្ពស់អភិបាលកិច្ចល្អ សិទ្ធិមនុស្ស ប្រព័ន្ធយុត្តិធម៌ ការអប់រំ សុខភាព ធនធានធម្មជាតិ និងបរិស្ថាន។ល។

គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៩នេះ មានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលបានតម្កល់សំណុំឯកសារ និងចុះបញ្ជីចំនួនសរុប**៥.៥៦៤** ក្នុងនោះសមាគមចំនួន**២.២៤៨** និងអង្គការមិនមែនរដ្ឋាភិបាលចំនួន**៣.៣១៦**។ បន្ទាប់ពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវចូលជាធរមាន សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មានចំនួន**សរុប៩៦៦** ត្រូវបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ស្របតាមច្បាប់ស្តីពី

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងនោះសមាគមចំនួន**៤៧១** និងអង្គការមិនមែនរដ្ឋាភិបាល**ចំនួន៤៩៥។** ដោយឡែក នៅក្នុងឆ្នាំ២០១៩នេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល**ចំនួន៣៨** ត្រូវបានលុបឈ្មោះចេញពីបញ្ជី តាមសំណើរបស់សាមីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ស្របតាមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ទោះបីជាយ៉ាងនេះក្តី ក៏ចំនួននៃការបង្កើតសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកថ្មីប្រចាំខែនីមួយៗមិនមានការថយចុះឡើយ ដែលជាមធ្យមក្នុងមួយខែមានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកដែលត្រូវបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ប្រហែលចំនួន**២០**។

ទន្ទឹមនឹងនេះ ផ្អែកលើគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ រដ្ឋបាលរាជធានី ខេត្តទាំងអស់ បានរៀបចំវេទិកាពិគ្រោះយោបល់រវាងរដ្ឋបាលរាជធានី ខេត្ត ជាមួយនឹងអង្គការសង្គមស៊ីវិលដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប្រចាំឆ្នាំ២០១៩ ចំនួន២(ពីរ) លើក រួចមកហើយ ដោយបានធ្វើការដោះស្រាយនូវសំណើ សំណូមពរ និងកង្វល់របស់អង្គការសង្គមស៊ីវិលបានយ៉ាងល្អប្រសើរ។ លើសពីនេះ ក្រសួងមហាផ្ទៃបានពិនិត្យឃើញជាទូទៅថា ការធ្វើសកម្មភាពរបស់អង្គការសង្គមស៊ីវិលនៅតាមមូលដ្ឋាន មានភាពល្អប្រសើរជាធម្មតា ដោយមិនមានការរឹតត្បិត នោះឡើយ។ ជាមួយគ្នានេះ អាជ្ញាធរមូលដ្ឋាន ហាក់មានការយល់ដឹងច្រើន និងផ្តល់កិច្ចសហការកាន់តែច្រើនឡើងជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នានានៅមូលដ្ឋាន។

ជាក់ស្តែង ក្នុងអំឡុងឆមាសទី២ ឆ្នាំ២០១៩នេះ ក្រសួងមហាផ្ទៃ បានទទួលនូវសេចក្តីរាយការណ៍ចំនួនតែ២(ពីរ)ករណីប៉ុណ្ណោះ ដែលពាក់ព័ន្ធនឹងការសួរនាំពីអាជ្ញាធរមូលដ្ឋាន គឺនៅខេត្តបាត់ដំបង ដែលអាជ្ញាធរឃុំពុំចេញលិខិតបញ្ជាក់អាសយដ្ឋានទីស្នាក់ការរបស់អង្គការ និងខេត្តបន្ទាយមានជ័យ ដែលអាជ្ញាធរស្រុកបានតម្រូវឱ្យអង្គការដាក់លិខិតស្នើសុំក្នុងការធ្វើសកម្មភាពរបស់ខ្លួន ដែលករណីនេះគឺផ្ទុយទៅនឹងគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ។ ចំពោះករណីទាំងពីរនេះ ក្រុមការងារអន្តរក្រសួងក៏បានធ្វើការទំនាក់ទំនងដោយផ្ទាល់ទៅរដ្ឋបាលខេត្តទាំងពីរ ដើម្បីជួយសម្របសម្រួល និងដោះស្រាយបញ្ហាដែលបានកើតឡើងនោះបានរួចរាល់ផងដែរ។ ទោះបីយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលកម្ពុជានៅតែមានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការបន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូ

យ៉ាងពិតប្រាកដ ជាមួយអង្គការសង្គមស៊ីវិល ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅតាមមូលដ្ឋាន។ ទន្ទឹមនឹងនេះ ខ្ញុំសូមអនុញ្ញាតជម្រាបជូនអង្គវេទិកាថា ក្រសួងមហាផ្ទៃ បាន និងកំពុងសហការជាមួយកម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ (UNDP) ដោយមានការគាំទ្រពីស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា ដើម្បីពង្រឹងសមត្ថភាពរបស់អង្គការសង្គមស៊ីវិល និងមន្ត្រីរាជរដ្ឋាភិបាល ក្នុងការចូលរួមចំណែកពង្រឹងដំណើរការលទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅកម្ពុជា។

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គវេទិកាទាំងមូលជាទីមេត្រី!**

ខ្ញុំសូមអនុញ្ញាតគូសបញ្ជាក់ដោយសង្ខេបអំពីសំណើធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ថា រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងមហាផ្ទៃសូមស្វាគមន៍ និងទទួលយកសំណើសុំធ្វើវិសោធនកម្មចំនួន ១៧មាត្រា ដែលបានស្នើដោយអង្គការសង្គមស៊ីវិល មកធ្វើការពិនិត្យ និងពិចារណា ហើយបានចាត់ឱ្យក្រុមការងាររបស់រាជរដ្ឋាភិបាល ដើម្បីដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល ដើម្បីធ្វើការសិក្សាចំពោះសំណើ និងអនុសាសន៍របស់អង្គការសង្គមស៊ីវិលពាក់ព័ន្ធនឹងការធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងបានធ្វើការប្រជុំពិភាក្សា និងពិគ្រោះយោបល់ជាមួយក្រុមអង្គការសង្គមស៊ីវិល **បានចំនួន៣លើក ដោយបានពិភាក្សាគ្នាបានចំនួន៥មាត្រា** រួចមកហើយ ដើម្បីស្វែងយល់បន្ថែមពីគោលបំណង មូលហេតុ និងខ្លឹមសារនៃការស្នើសុំធ្វើវិសោធនកម្ម ប៉ុន្តែ ការពិភាក្សាលើសំណើសុំធ្វើវិសោធនកម្មច្បាប់នេះមានភាពយឺតយ៉ាវ ដោយសារតែតំណាងក្រុមអង្គការសង្គមស៊ីវិលនៅមិនទាន់មានភាពស្រុះស្រួល និងឯកភាពគ្នាលើខ្លឹមសារ គោលបំណង និងមូលហេតុនៃការស្នើសុំធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលជាហេតុធ្វើឲ្យដំណើរការនៃការពិគ្រោះយោបល់នេះ ត្រូវការពេលវេលាសមស្រប ដើម្បីទទួលបាននូវលទ្ធផលជាវិជ្ជមាន។ ប៉ុន្តែទោះជាយ៉ាងនេះក្តី រាជរដ្ឋា-ភិបាលនៅតែមានឆន្ទៈក្នុងការបន្តដំណើរការប្រជុំពិគ្រោះយោបល់ជាមួយក្រុមតំណាងអង្គការសង្គមស៊ីវិល រហូតទទួលបានលទ្ធផលជាវិជ្ជមាន ដែលកិច្ចប្រជុំពិគ្រោះយោបល់លើកទី៤ លើសំណើសុំធ្វើវិសោធនកម្មច្បាប់នេះ គ្រោងនឹងរៀបចំឡើងនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ខាងមុខនេះ។

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គវេទិកាទាំងមូលជាទីមេត្រី!**

ឆ្លៀតក្នុងឱកាសនៃការជួបជុំគ្នានាថ្ងៃនេះ ក្នុងនាមរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមអំពាវនាវដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដូចខាងក្រោម៖

**១**-សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ និងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលបានចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបន្តអនុវត្តសកម្មភាពរបស់ខ្លួនឱ្យបានត្រឹមត្រូវស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។ លើសពីនេះ សូមចៀសវាងជាដាច់ខាតនូវសកម្មភាពទាំងឡាយណាដែលអាចជាប់ពាក់ព័ន្ធ ឬគាំទ្រដល់ការលាងសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានអាវុធប្រល័យលោក ដើម្បីចៀសផុតពីការធ្វើឱ្យកម្ពុជាធ្លាក់ចូលទៅក្នុងបញ្ជីប្រផេះ និងទទួលបច្ច័យជាអវិជ្ជមានលើផ្នែកប្រព័ន្ធហិរញ្ញវត្ថុ លំហូរវិនិយោគ និងនយោបាយជាដើម។

**២**-ស្នើដល់អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ បន្តគាំទ្រ និងចូលរួមដោយស្មោះសរជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងដំណើរការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស ដើម្បីពង្រឹងនូវសុខសន្តិភាព ស្ថិរភាពសង្គម និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យកាន់តែរីកចម្រើនរុងរឿងបន្ថែមទៀត។ ក្រៅពីនេះ ស្នើឱ្យអង្គការសង្គមស៊ីវិលបន្តចូលរួមក្នុងការការពារធនធានធម្មជាតិ និងបរិស្ថាន ការទប់ស្កាត់បទល្មើសកាប់បំផ្លាញព្រៃឈើ និងការនេសាទខុសច្បាប់ ការជួញដូរមនុស្ស ការផលិត និងចែកចាយគ្រឿងញៀន ព្រមទាំងចូលរួមក្នុងការអប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីច្បាប់ស្តីពីចរាចរផ្លូវគោក ។ល។

**៣**-ស្នើឱ្យអង្គការសង្គមស៊ីវិលបន្តចូលរួមក្នុងវិស័យកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ជាពិសេសកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលថ្មីៗនេះ រាជរដ្ឋាភិបាលបានផ្ទេរមុខងារចំនួន ៥៥មុខងារ ក្នុងវិស័យចំនួន១៨ រួមទាំងធនធានចាំបាច់នានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រង និងចាត់ចែងមុខងារ និងធនធានទាំងនោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន តាមរយៈការដាក់

ចេញនូវអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ព្រមទាំងការសម្រេចបង្កើនថវិកាផ្នែកអភិវឌ្ឍន៍មូលដ្ឋាន ដល់រដ្ឋបាលឃុំ សង្កាត់ ដែលនឹងត្រូវអនុវត្តចាប់ពីឆ្នាំ២០២០នេះ។ ពាក់ព័ន្ធនឹងករណីនេះ ខ្ញុំសូមអំពាវនាវដល់អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ មេត្តាបន្តចូលរួម និងគាំទ្រនៅក្នុងដំណើរការកំណែទម្រង់នេះ ដូចជា ការជួយកសាងសមត្ថភាពដល់មន្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការបន្តពង្រឹងយន្តការគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការពង្រឹងភាពជាម្ចាស់របស់រដ្ឋបាលមូលដ្ឋានក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយតម្លាភាព គណនេយ្យភាព និងមានប្រសិទ្ធភាព។ល។

ទន្ទឹមនេះដែរ ខ្ញុំសូមធ្វើការណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបន្តយកចិត្តទុកដាក់អនុវត្តនូវការងារមួយចំនួនដូចខាងក្រោម៖

**ទីមួយ**៖ត្រូវបន្តសម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់អង្គការសង្គមស៊ីវិលដែលបានចុះបញ្ជីត្រឹមត្រូវ ព្រមទាំងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលបានចុះអនុស្សរណៈជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការធ្វើសកម្មភាពដោយសេរី និងគ្មានការរឹតត្បិត ស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

**ទីពីរ**៖រដ្ឋបាលរាជធានី ខេត្ត ត្រូវបន្តរៀបចំវេទិកាស្តីពីភាពជាដៃគូរវាងរដ្ឋបាលរាជធានី ខេត្ត ជាមួយអង្គការសង្គមស៊ីវិលដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឱ្យបានយ៉ាងហោចចំនួន២ដង ក្នុង១ឆ្នាំ តាមការកំណត់ ដោយត្រូវរាយការណ៍ជូនក្រសួងមហាផ្ទៃអំពីកាលបរិច្ឆេទនៃការរៀបចំវេទិកា និងលទ្ធផលនៃវេទិកាផងដែរ។

**ទីបី**៖ រដ្ឋបាលរាជធានី ខេត្ត ត្រូវណែនាំដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាទៀងទាត់យ៉ាងហោចចំនួន២ដង ក្នុង១ឆ្នាំ រវាងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាមួយនឹងសហគមន៍នានានៅមូលដ្ឋាន ដូចជា សហគមន៍ព្រៃឈើ សហគមន៍នេសាទ សមាគមមនុស្សចាស់ ជាដើម ដោយមានការចូលរួមពីមន្ត្រីជំនាញនៃមន្ទីរ អង្គភាពពាក់ព័ន្ធនានានៅថ្នាក់រាជធានី ខេត្ត។

ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលទាំងអស់ដែលបានចូល រួមចំណែកយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជានាពេលកន្លងមក ដោយបានផ្តល់នូវការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសជាច្រើនក្នុងកិច្ចការអភិវឌ្ឍន៍ប្រទេសកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិកា នៃអង្គវេទិកាទាំងមូល សូមជួបប្រទះតែនឹងព្រះពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសបើកវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលលើកទី៤ ចាប់ពីពេលនេះតទៅ។

*សូមអរគុណ*